# សេចក្តីប្រកាសព័ត៌មាន

សហព័ន្ធស្រូវអង្ករកម្ពុជានិងក្រុមហ៊ុនហ្គ្រីនត្រេដនៃក្រសួងពាណិជ្ជកម្ម មានកិត្តិយស សូមជំរាបជូនថា ដោយសារព័ត៌មាននៃការរីករាលដាល់នៃជម្ងឺឆ្លង កូវីត១៩ បានធ្វើអោយមានក្តីបារម្ភរបស់ប្រជាជន ប្រជាជនកម្ពុជាយើងដែលជះឥទ្ធិពលលើតម្លៃរស្បៀងអាហារ ជាពិសេសមានឈ្មួញមួយចំនួនបានតម្លើងថ្លៃអង្ករ។ ឆ្លៀតឱកាសនេះសហព័ន្ធស្រូវអង្ករកម្ពុជា និងក្រុមហ៊ុនហ្គ្រីនត្រេដ នៃក្រសួងពាណិជ្ជកម្មសូមជម្រាបជូនដល់បងប្អូន ប្រជាពលរដ្ឋកម្ពុជាយើងអោយបានជ្រាបថា បរិមាណសន្និធិអង្ករ និងស្រូវមិនទាន់កិន របស់សមាជិកសហព័ន្ធស្រូវអង្ករកម្ពុជានៅទូទាំងប្រទេសលើទីតាំងចំនួនជាង ៩០០ រោងម៉ាស៊ីនកិនស្រូវ គឺមានបរិមាណគ្រប់គ្រាន់ សំរាប់ផ្គត់ផ្គង់ជូនតាមតម្រូវការក្នុងស្រុក និងសំរាប់នាំចេញ រហូតដល់រដូវប្រមូលផលខាងមុខ។

អាស្រ័យដូចនេះសហព័ន្ធស្រូវអង្គកម្ពុជា និងក្រុមហ៊ុនហ្គ្រីនត្រេដនៃក្រសួងពាណិជ្ជកម្មសូមអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋកុំ មានការភ័យព្រួយបារម្ភលើបញ្ហាខ្វះអង្ករ ដែលជាហេតុនាំអោយមានជនឆ្លៀតឱកាសនិយម មួយចំនួនដែលឆ្លៀតដំឡើងថ្លៃអង្ករ។

ដើម្បីដោះស្រាយកង្វល់ និងទប់ស្កាត់ស្ថានការណ៍ពីជនឆក់ឱកាសនិយមតំឡើងថ្លៃអង្ករ សហព័ន្ធស្រូវអង្ករកម្ពុជា នឹងសហការជាមួយក្រុមហ៊ុន ហ្គ្រីនត្រេដនៃក្រសួងពាណិជ្ជ កម្ម នឹងបើកលក់អង្ករចាប់តាមកាលបរិច្ឆេត និងទីកន្លែងចាប់ពី ថ្ងៃច័ន្ទទី ៩ ខែមិនា ឆ្នាំ២០២០ តាមទីតាំងរួមមាន ៖

- ស្នាក់ការក្រុមហ៊ុន ហ្គ្រីនត្រេដ អាគារលេខ៦៥-៦៧-៦៩ ផ្លូវលេខ ១៣៦ សង្កាត់ផ្សារកណ្តាល១ រាជធានីភ្នំពេញ លេខទូរស័ព្ទ លេខ 012 595856
- មណ្ឌលឃ្លាំង ក្រុមហ៊ុន ហ្គ្រីន ត្រេដ ផ្លូវជាតិ លេខ៥ ភូមិស្ពានខ្ពស់ សង្កាត់គីឡូម៉ែត្រ លេខ៦ ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ក្នុងតម្លៃលក់ ដូចខាងក្រោម៖
- <u>អង្ករសែនក្រអូប ១បេ ៥០គីឡូក្រាម 152,000 រៀល ( តំលៃលក់នៅទីតាំងផ្ទាល់)</u>

ក្រៅពីនេះបងប្អូនអាចរកស្វែងរកទិញផ្ទាល់ពីសមាជិកសហព័ន្ធស្រូវអង្ករកម្ពុជាដូចជា៖ ក្រុមហ៊ុនមេគង្គអូរីហ្សា 069 228 292 -ក្រុមហ៊ុនអេមរ៉ូរាយ 011 626306 - ក្រុមហ៊ុនបៃតងកម្ពុជា 095717171/069343434 -ក្រុមហ៊ុនខ្មែរហ្វៀតគ្រុប089222028/089222032-រោងម៉ាស៊ីនវង្សប៊ុនហេង 085545888 -រោងម៉ាស៊ីន អៀងហ៊ាង 085242645/089459998 - រោងម៉ាស៊ីន ហាក់ សែ 012 500400/010650651

**សេវាដឹកជញ្ជូនដល់ទីតាំង**

ក្រុមហ៊ុននែតជ្រល អហ្គ្រោត្រេត ឯ.ក 012 863012/015863012/086211616